# ពោជ្ឈង្គបរិត្ត (បិដក៣៧ ទំព័រ២០៥)

## (បិដក អដ្ឋកថា ដីកា)



រៀបរៀងដោយភិក្ខុ នួន សារ៉េត ព.ស២៥៦៦, គ.ស២០២៣

# សេចក្ដីផ្ដើម

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុ សារត្ថធម្មោ នួន សារ៉េត បានរៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទទូទៅ បានការសិក្សាស្រាវជ្រាវ និង បដិបត្តិក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ ដល់សង្គមជាតិ សាសនា របស់ខ្មែរយើង នឹងជួយជាចំណេះដឹង ដល់កុលបុត្រ កុលធីតា ប្អូនៗ បងៗ ជានិស្សិត ក្នុងសៀវភៅនេះផងដែរ ។

ពិតណាស់ សង្គមមួយ ដែលមានមនុស្សចេះដឹងច្រើន យល់ដឹងច្រើន នឹងឈានទៅរកការអភិវឌ្ឍបានរីកចម្រើន ភាពសម្បូរសប្បាយ លូតលាស់ ជឿនលឿន ប្រកបដោយសុខចម្រើន ក្នុងសង្គមនោះពុំខាន ។ ហេតុនេះហើយ ខ្ញុំព្រះករុណា អាត្មាភាព នឹងសង្ឃឹមថា សៀវភៅនេះ នឹងបានជាយោជន៍ដល់ជនច្រើន ។

សេចក្ដីរៀបរាប់មកខាងលើនេះ សូមជូនពរ ឲ្យពុទ្ធបរិស័ទទាំងអស់ និង ប្អូនៗ បងៗ សិក្សា បដិបត្តិ ឲ្យបានជាប្រយោជន៍ ជាចំណេះដឹង ជាមេរៀន ជាមេគំនិត សម្រាប់ដំណើរជីវិតនេះ ប្រកបតែសេចក្ដីសុខ សេចក្ដីចម្រើន និង រួចចាកទុក្ខទាំងពួង កុំបីអាក់ខានឡើយ ។

សូមថ្វាយព្រះរាជកុសលនេះ ដល់ព្រះមហាក្សត្រាក្សត្រីខ្មែរគ្រប់ជំនាន់ និងថ្វាយព្រះរាជកុសលដល់ព្រះសង្ឃរាជទាំងទាំងពីរគណៈគ្រប់ជំនាន់ និងមន្ត្រីសង្ឃគ្រប់រូប ព្រមទាំងបុព្វបុរសវីរៈជនខ្មែរគ្រប់រូប ពុទ្ធបរិស័ទទាំងអស់ សូមអនុមោទនានូវធម្មទានដែលខ្ញុំព្រះករុណា អាត្មាភាព បានបំពេញនេះ ហើយសូមឲ្យតែបានសេចក្ដីសុខ សេចក្ដីចម្រើន និងរួចចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

វត្តស្រះមុជ្ជលិន្ទ ថ្ងៃទី២០ ខែមេសាឆ្នាំ២០២៣

សារត្ថធម្មោ នួន សារ៉េត

# ពោជ្ឈង្គបរិត្ត គិលានវគ្គ

## ពោជ្ឈង្គបរិត្ត[១]

(បិដកលេខ ៣៧ ទំព័រ ២០៥)

**ពោជ្ឈង្គោ សតិសង្ខាតោ ធម្មានំ វិចយោ តថា**
**វីរិយម្បីតិបស្សទ្ធិ ពោជ្ឈង្គា ច តថាបរេ**
**សមាធុបេក្ខាពោជ្ឈង្គា សត្តេតេ សព្វទស្សិនា**
**មុនិនា សម្មទក្ខាតា ភាវិតា ពហុលីកតា**

*ពោជ្ឈង្គទាំងឡាយ ៧ ប្រការនេះ គឺសតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ដែលព្រះមុនីជាម្ចាស់ទ្រង់ជ្រាបនូវធម៌ទាំងពួងត្រាស់សម្តែងហើយដោយប្រពៃ គឺបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ*

**សំវត្តន្តិ អភិញ្ញាយ និព្វានាយច ពោធិយា** *តែងប្រព្រឹត្តទៅដើម្បីសេចក្តីដឹងក្រៃពេកផង ដើម្បីកិរិយាចេញចាកតណ្ហាផង ដើម្បីកិរិយាត្រាស់ដឹងផង*

**ឯតេន សច្ចវជ្ជេន សោត្ថិ តេ ហោតុ សព្វទា** *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នកសព្វ ៗ កាល*

**ឯកស្មិំ សមយេ នាថោ មោគ្គល្លានញ្ច កស្សបំ**
**គិលានេ ទុក្ខិតេ ទិស្វា ពោជ្ឈង្គេ សត្ត ទេសយិ**

*ក្នុងសម័យមួយ ព្រះលោកនាថជាម្ចាស់ ទ្រង់ឃើញនូវព្រះមោគ្គល្លាននិងព្រះកស្សបៈមានជំងឺ ដល់នូវទុក្ខវេទនា ហើយទ្រង់សម្តែងនូវពោជ្ឈង្គទាំងឡាយ*

---

១-ពាក្យដើមឈ្មោះថា គិលានសូត្រ មាន ៣ សូត្រ គឺបឋមគិលានសូត្រ ទុតិយគិលានសូត្រ និងតតិយគិលានសូត្រ ។

*៧ ប្រការ*

**តេ ច តំ អភិនន្ទិត្វា រោគា មុច្ចឹសុ តំខណេ** *ព្រះថេរៈទាំងពីរអង្គនោះក៏រីករាយចំពោះព្រះពុទ្ធភាសិតនោះ ហើយបានជាសះស្បើយចាករោគក្នុងមួយរំពេចនោះ*

**ឯតេន សច្ចវជ្ជេន សោត្ថិ តេ ហោតុ សព្វទា** *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នកសព្វ ៗ កាល ។*

**ឯកទា ធម្មរាជាបិ គេលញ្ញេនាភិបីឡិតោ** *ក្នុងគ្រាមួយ ព្រះសម្ពុទ្ធជាព្រះធម្មរាជ ដែលគិលានរោគបៀតបៀនហើយ*

**ចុន្ទត្ថេរេន តញ្ញេវ ភណាបេត្វាន សាទរំ** *ទ្រង់ត្រាស់ប្រើព្រះចុន្ទត្ថេរឱ្យសម្តែងនូវពោជ្ឈង្គនោះដែរ ដោយអើពើហើយ*

**សម្មោទិត្វា ច អាពាធា តម្ហា វុដ្ឋាសិ ឋានសោ** *ទ្រង់រីករាយហើយជា-សះស្បើយចាកអាពាធនោះក្នុងមួយរំពេចនោះ*

**ឯតេន សច្ចវជ្ជេន សោត្ថិតេ ហោតុ សព្វទា** *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នកសព្វ ៗ កាល ។*

**បហីនា តេ ច អាពាធា តិណ្ណន្នម្បិ មហេសិនំ** *ក៏អាពាធទាំងឡាយនោះដែលព្រះអរិយបុគ្គលទាំង ៣ ព្រះអង្គ លោកជាអ្នកស្វែងរកនូវគុណធម៌ដ៏ធំលះបង់ គឺថាលោកបានជាសះស្បើយហើយ*

**មគ្គាហតកិលេសា វ បត្តានុប្បត្តិធម្មតំ** *ដល់ហើយនូវធម្មតា គឺកិរិយាមិន*

*កើត (ទៀត) ដូចជាកិលេសដែលព្រះអរិយបុគ្គលកម្ចាត់ហើយដោយព្រះអរិយមគ្គ*

**ឯតេន សច្ចវជ្ជេន សោត្ថិ តេ ហោតុ សព្វទា** *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នកសព្វ ៗ កាល ។*

**(ត្រង់នេះសម្រាប់សូធ្យស្វាធ្យាយ)**

**ពោជ្ឈង្គបរិត្ត គិលានវគ្គ (បិដក៣៧ ទំព័រ២០៥)**

[៤០៩] ម្នាលភិក្ខុទាំងឡាយ ដូចសត្វទាំងឡាយណាមួយ សម្រេចឥរិយាបថទាំង៤ គឺដើរតាមកាល ឈរតាមកាល អង្គុយតាមកាល ដេកតាមកាល សត្វទាំងអស់នោះ អាស្រ័យផែនដី តាំងស៊ប់លើផែនដី ទើបសម្រេចឥរិយាបថ ទាំង៤នោះ យ៉ាងនេះឯង យ៉ាងណាមិញ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យសីល តាំងមាំក្នុងសីល ទើបចំរើនពោជ្ឈង្គ ទាំង៧ ធ្វើឲ្យរឿយៗនូវពោជ្ឈង្គទាំង៧ បាន ក៏យ៉ាងនោះដែរ។

[៤១០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យសីល តាំងមាំក្នុងសីល ទើបចំរើនពោជ្ឈង្គ ទាំង៧ ធ្វើឲ្យរឿយៗនូវពោជ្ឈង្គ ទាំង៧ បាន តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យការប្រាសចាករាគៈ អាស្រ័យសេចក្តីរលត់ ដែលទន់ទោរ ទៅក្នុងការលះបង់។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីប្រាសចាករាគៈ អាស្រ័យសេចក្តីរលត់ ដែលទន់ទោរ ទៅក្នុងការលះបង់។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យសីល តាំងមាំក្នុងសីល តែងចំរើនពោជ្ឈង្គ ទាំង៧ ធ្វើឲ្យរឿយៗនូវពោជ្ឈង្គ ទាំង៧ យ៉ាងនេះឯង។

[៤១១] ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃអរុណនុ៎ះឯង ជាប្រធាន ជាបុព្វនិមិត្តនៃព្រះអាទិត្យ ដែលកើតឡើង (យ៉ាងណា) ភាវៈនៃកល្យាណមិត្តនុ៎ះឯង ជាប្រធាន ជាបុព្វនិមិត្តនៃការញុំាងពោជ្ឈង្គ ទាំង៧ ឲ្យកើតឡើងដល់ភិក្ខុ ក៏យ៉ាងនោះដែរ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ ភិក្ខុដែលនឹងចំរើននូវពោជ្ឈង្គ ទាំង៧ ធ្វើឲ្យរឿយៗនូវពោជ្ឈង្គទាំង៧ (នោះ) គួរប្រាថ្នានូវភិក្ខុ ដែលជាកល្យាណមិត្ត (កុំខាន)។

[៤១២] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមានកល្យាណមិត្ត រមែងចំរើនពោជ្ឈង្គ ទាំង៧ធ្វើឲ្យរឿយៗនូវពោជ្ឈង្គ ទាំង៧ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ អាស្រ័យសេចក្តីស្ងប់ស្ងាត់។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យការប្រាសចាករាគៈ អាស្រ័យសេចក្តីរលត់ ដែលទន់ទោរ ទៅក្នុងការលះបង់។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកល្យាណមិត្ត តែងចំរើននូវពោជ្ឈង្គ ទាំង៧ ធ្វើឲ្យរឿយៗនូវពោជ្ឈង្គ ទាំង៧ យ៉ាងនេះឯង។

[៤១៣] ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃអរុណនុ៎ះ ជាប្រធាន ជាបុព្វនិមិត្តនៃព្រះអាទិត្យ ដែលកើតឡើង (យ៉ាងណា) ម្នាលភិក្ខុទាំងឡាយ យោនិសោមនសិការ (ការធ្វើទុកក្នុងចិត្ត ដោយឧបាយ) នុ៎ះជាប្រធាន ជាបុព្វនិមិត្តនៃការញុំាងពោជ្ឈង្គ ទាំង៧ ឲ្យកើតឡើងដល់ភិក្ខុ ក៏យ៉ាងនោះឯង។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ ភិក្ខុដែលនឹងចំរើននូវពោជ្ឈង្គ ទាំង៧ ធ្វើឲ្យរឿយៗនូវពោជ្ឈង្គ ទាំង៧ (នោះ) គួរប្រាថ្នានូវភិក្ខុ ដែលបរិបូណ៌ ដោយយោនិសោមនសិការ (កុំខាន)។

[៤១៤] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុដែលបរិបូណ៌ ដោយយោនិសោមនសិការ រមែងចំរើននូវពោជ្ឈង្គ ទាំង៧ ធ្វើឲ្យរឿយៗនូវពោជ្ឈង្គ ទាំង៧ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់។បេ។ ចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យការប្រាសចាករាគៈ អាស្រ័យសេចក្តីរលត់ ដែលទន់ទោរ ទៅក្នុងការលះបង់។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ ដោយយោនិសោមនសិការ រមែងចំរើននូវពោជ្ឈង្គ ទាំង៧ ធ្វើឲ្យរឿយៗនូវពោជ្ឈង្គ ទាំង៧ យ៉ាងនេះឯង។

[៤១៥] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ។ សម័យនោះឯង ព្រះមហាកស្សបដ៏មានអាយុ គង់នៅក្នុងបិប្ផលិគុហា លោកមានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺជាទម្ងន់។

[៤១៦] គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ទ្រង់ចូលទៅរកព្រះមហាកស្សបដ៏មានអាយុ លុះចូទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈ ដែលគេក្រាលទុក។ លុះព្រះដ៏មានព្រះភាគ គង់ហើយ ទ្រង់មានព្រះពុទ្ធដីកា នឹងព្រះមហាកស្សបដ៏មានអាយុ ដូច្នេះថា ម្នាលកស្សប សរីរយន្តរបស់អ្នក ល្មមអត់ធន់បានខ្លះដែរឬ ល្មមឲ្យប្រព្រឹត្តទៅបានដែរឬ ទុក្ខវេទនាធូរថយ មិនចំរើនឡើង មានតែស្រាកស្រាន្តទៅ មិនរឹតឡើងទេឬ។ បពិត្រព្រះអង្គដ៏ចំរើន

សរិរយន្តរបស់ខ្ញុំព្រះអង្គ មិនល្មមអត់ធន់បានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គ ក្លៀវក្លាខ្លាំងណាស់ មិនធូរថយទេ មានតែរឹតឡើង មិនស្រាកស្រាន្តទេ។

[៤១៧] ម្នាលកស្សប ពោជ្ឈង្គ ទាំង៧នេះ ដែលតថាគត សំដែងប្រពៃហើយ បានចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន។ ពោជ្ឈង្គ ទាំង៧ តើអ្វីខ្លះ។

[៤១៨] ម្នាលកស្សប សតិសម្ពោជ្ឈង្គ ដែលតថាគត បានសំដែងប្រាប់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែប្រព្រឹត្តទៅ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន។បេ។ ម្នាលកស្សប ឧបេក្ខាសម្ពោជ្ឈង្គ ដែលតថាគត សំដែងប្រាប់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បនិព្វាន។ ម្នាលកស្សប សម្ពោជ្ឈង្គ ទាំង៧ នេះឯង ដែលតថាគត សំដែងប្រាប់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន។

[៤១៩] បពិត្រព្រះដ៏មានព្រះភាគ ពិតមែនហើយ ពោជ្ឈង្គទាំងឡាយ បពិត្រព្រះសុគត ពិតមែនហើយ ពោជ្ឈង្គទាំងឡាយ។ លុះព្រះដ៏មានព្រះភាគ បានត្រាស់ធម៌នេះចប់ហើយ។ ព្រះមហាកស្សបដ៏មានអាយុ ក៏ត្រេកអរ ចំពោះភាសិត របស់ព្រះដ៏មានព្រះភាគ។ ឯព្រះមហាកស្សបដ៏មានអាយុ ក៏បានជាសះស្បើយ ចាកអាពាធនោះ មួយទៀត អាពាធនោះ ក៏ព្រះមហាកស្សបដ៏មានអាយុ បានលះបង់ យ៉ាងនោះហើយ។

[៤២០] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ។ សម័យនោះឯង ព្រះមហាមោគ្គល្លានដ៏មានអាយុ គង់នៅជិតភ្នំគិជ្ឈកូដ មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់។

[៤២១] គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ទ្រង់ចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ។ លុះព្រះដ៏មានព្រះភាគ ទ្រង់គង់ហើយ ក៏មានព្រះពុទ្ធដីកា នឹងព្រះមហាមោគ្គល្លាន ដ៏មានអាយុ ដូច្នេះថា ម្នាលមោគ្គល្លាន សរីរយន្តរបស់អ្នក ល្មមអត់ធន់បានខ្លះដែរឬ អ្នកល្មមឲ្យប្រព្រឹត្តទៅបានខ្លះដែរឬ ទុក្ខវេទនាធូរថយទៅ មិនចំរើនឡើង មានតែស្រាកស្រាន្តទៅ មិនរឹតឡើងទេឬ។ បពិត្រព្រះអង្គដ៏ចំរើន សរីរយន្តរបស់ខ្ញុំព្រះអង្គ មិនល្មមអត់ធន់បានទេ មិនល្មមឲ្យប្រព្រឹត្ត

ទៅបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គ ធ្ងន់ពេកណាស់ មិនធូរថយទេ មានតែរឹតឡើង មិនស្រាកស្រាន្តទេ។

[៤២២] នែមោគ្គល្លាន ពោជ្ឈង្គ ទាំង៧នេះ ដែលតថាគត សំដែងប្រាប់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន។ សម្ពោជ្ឈង្គ ទាំង៧ តើដូចម្តេចខ្លះ។

[៤២៣] ម្នាលមោគ្គល្លាន សតិសម្ពោជ្ឈង្គ ដែលតថាគតសំដែងប្រាប់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន។ បេ។ ម្នាលមោគ្គល្លាន ឧបេក្ខាសម្ពោជ្ឈង្គ ដែលតថាគតសំដែងប្រាប់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន។ ម្នាលមោគ្គល្លាន ពោជ្ឈង្គ ទាំង៧ នេះឯង ដែលតថាគត សំដែងប្រាប់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន។

[៤២៤] បពិត្រព្រះដ៏មានព្រះភាគ ពិតមែនហើយ ពោជ្ឈង្គទាំងឡាយ បពិត្រព្រះសុគត ពិតមែនហើយ ពោជ្ឈង្គទាំងឡាយ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ធម៌នេះចប់ហើយ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ត្រេកអរ រីករាយ ចំពោះភាសិត របស់ព្រះដ៏មានព្រះភាគ។ ឯព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏បានជាសះស្បើយ ចាកអាពាធនោះ អាពាធនោះ ក៏ព្រះមហាមោគ្គល្លានបានលះបង់ យ៉ាងនោះហើយ។

[៤២៥] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ។ សម័យនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់។

[៤២៦] គ្រានោះឯង ព្រះមហាចុន្ទដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះព្រះមហាចុន្ទដ៏មានអាយុ គង់ក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគបានត្រាស់ ដូច្នេះថា ម្នាលចុន្ទ ចូរអ្នកសំដែងពោជ្ឈង្គទាំងឡាយ។ បពិត្រព្រះអង្គដ៏ចំរើន ពោជ្ឈង្គ ទាំង៧នេះ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន។ ពោជ្ឈង្គ ទាំង៧ តើដូចម្តេចខ្លះ។

[៤២៧] បពិត្រព្រះអង្គដ៏ចំរើន សតិសម្ពោជ្ឈង្គ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន។បេ។ បពិត្រព្រះអង្គដ៏ចំរើន ឧបេក្ខាសម្ពោជ្ឈង្គ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន។ បពិត្រព្រះអង្គដ៏ចំរើន ពោជ្ឈង្គ ទាំង៧នេះឯង ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន។

[៤២៨] ម្នាលចុន្ទ ពិតមែនហើយ ពោជ្ឈង្គទាំងឡាយ ម្នាលចុន្ទ ពិតមែនហើយ ពោជ្ឈង្គទាំងឡាយ។ លុះព្រះមហាចុន្ទដ៏មានអាយុ សំដែងនូវធម៌នេះចប់ហើយ ព្រះសាស្ដា ក៏ទ្រង់ពេញព្រះហឫទ័យ។ ព្រះដ៏មានព្រះភាគ ក៏បានជាសះស្បើយ ចាកអាពាធនោះ អាពាធនោះ ព្រះដ៏មានព្រះភាគ ក៏បានលះបង់ យ៉ាងនោះហើយ។

[៤២៩] ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គ ទាំង៧នេះ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយៗហើយ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យឃ្លាតចាកទី មិនមែនជាត្រើយ ឲ្យដល់ទីជាត្រើយ។ ពោជ្ឈង្គ ទាំង ៧ តើដូចម្ដេចខ្លះ។ គឺសតិសម្ពោជ្ឈង្គ១។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ១។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង៧នេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយៗហើយ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យឃ្លាតចាកទីមិនមែនជាត្រើយ ឲ្យដល់ទីជាត្រើយ។

[៤៣០] បណ្ដាមនុស្សទាំងឡាយ ជនទាំងឡាយឯណា ដល់នូវត្រើយ គឺព្រះនិព្វាន ជនទាំងឡាយនោះ មានចំនួនតិចទេ សត្វក្រៅពីនេះ សសៀរទៅតាមត្រើយ គឺវដ្តៈ។ ពួកជនណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលព្រះតថាគត សំដែងប្រាប់ប្រពៃហើយ ពួកជននោះ នឹងឆ្លងផុតទីកន្លែងរបស់មច្ចុ ដែលគេឆ្លងបានដោយលំបាកពេក ហើយដល់នូវត្រើយ គឺព្រះនិព្វានបាន។ បណ្ឌិតលះបង់នូវធម៌ខ្មៅ ហើយចំរើនធម៌ស ចេញចាកអាល័យ អាស្រ័យព្រះនិព្វាន ដែលគ្មានសេចក្ដីអាល័យហើយ គប្បីលះបង់កាមទាំងឡាយ ជាអ្នកឥតមានកង្វល់ ប្រាថ្នានូវសេចក្ដីត្រេកអរចំពោះក្នុងសេចក្ដីស្ងប់ស្ងាត់ ដែលសត្វត្រេកអរបាន ដោយកម្រនោះ បណ្ឌិតត្រូវធ្វើខ្លួនឲ្យផូរផង់ ចាកសេចក្ដីសៅហ្មងនៃចិត្ត ពួកជនណា បានចំរើនចិត្ត ដោយប្រពៃ ក្នុងសម្ពោជ្ឈង្គទាំងឡាយ ហើយមិនបាន

ប្រកាន់មាំ ត្រេកអរក្នុងការលះសេចក្តីប្រកាន់ ពួកជននោះ រមែងអស់អាសវៈ មានសេចក្តីរុងរឿង បរិនិព្វានហើយក្នុងលោក។

[៤៣១] ម្នាលភិក្ខុទាំងឡាយ ពួកជនណាមួយ លះបង់ពោជ្ឈង្គ ទាំង៧ ហើយ ពួកជននោះក៏ឈ្មោះថា លះបង់អរិយមគ្គ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យអស់ទុក្ខ ដោយប្រពៃដែរ។ ម្នាលភិក្ខុទាំងឡាយ អ្នកណាមួយ បានប្រារព្ធពោជ្ឈង្គ ទាំង៧ហើយ អ្នកនោះ ក៏ឈ្មោះថា បានប្រារព្ធអរិយមគ្គ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យអស់ទុក្ខ ដោយប្រពៃដែរ។ ពោជ្ឈង្គ ទាំង៧ តើដូចម្តេចខ្លះ។ គឺសតិសម្ពោជ្ឈង្គ១។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ១។

[៤៣២] ម្នាលភិក្ខុទាំងឡាយ ពួកជនណាមួយ លះបង់ពោជ្ឈង្គ ទាំង៧នេះ ពួកជននោះ ក៏ឈ្មោះថា លះបង់អរិយមគ្គ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យអស់ទុក្ខ ដោយប្រពៃ។ ម្នាលភិក្ខុទាំងឡាយ ពួកជនណាមួយ ប្រារព្ធពោជ្ឈង្គ ទាំង៧នេះ ពួកជននោះក៏ឈ្មោះថា បានប្រារព្ធនូវអរិយមគ្គ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យអស់ទុក្ខ ដោយប្រពៃដែរ។

[៤៣៣] ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គ ទាំង៧នេះ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយៗហើយ ជាធម៌ប្រសើរ ជាទីស្រោចស្រង់សត្វ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យអស់ទុក្ខ ដល់អ្នកចំរើនពោជ្ឈង្គនោះ។ ពោជ្ឈង្គ ទាំង៧ តើដូចម្តេចខ្លះ។ គឺសតិសម្ពោជ្ឈង្គ១។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ១។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គ ទាំង៧នេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយៗហើយ ជានិយ្យានិកធម៌ ដ៏ប្រសើរ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យអស់ទុក្ខ ដោយប្រពៃ ដល់អ្នកចំរើនពោជ្ឈង្គនោះ។

[៤៣៤] ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គ ទាំង៧នេះ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយៗហើយ រមែងប្រព្រឹត្តទៅ ដើម្បីនឿយណាយដោយពិត ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់ ដើម្បីចូលទៅជិតរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន។ ពោជ្ឈង្គ ទាំង៧ តើដូចម្តេចខ្លះ។ គឺសតិសម្ពោជ្ឈង្គ១។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ១។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គ ទាំង៧នេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយៗហើយ រមែងប្រព្រឹត្តទៅ ដើម្បីនឿយណាយដោយពិត ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់ ដើម្បីចូលទៅជិតរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន។

(ចប់ គិលានវគ្គ ទី២ ក្នុងបិដក)

# គិលានវគ្គទី ២

## អ ដ្ឋ ក ថា

### បាណូបមសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង **បាណូបមសូត្រទី ១ នៃ គិលានវគ្គទី ១** ។*

[៤០៩] *បទថា **សម្រេចឥរិយាបថ ៤ (ចត្តារោ ឥរិយាបថេ កប្បេន្តិ)** សេចក្តីថា ឥរិយាបថ ៤ របស់សត្វពួកណាមានហើយ ពាក្យនោះ លោកពោលដោយអំណាចនៃសត្វទាំងនោះប៉ុណ្ណោះ ។ បទថា **អាស្រ័យសីល (សីលំ និស្សាយ)** បានដល់ ធ្វើចតុប្បារិសុទ្ធិសីលឲ្យជាទីអាស្រ័យ ។ បទថា **ពោជ្ឈង្គៈ ៧ (សត្ត ពោជ្ឈង្គេ)** បានដល់ ពោជ្ឈង្គៈដែលជាមគ្គ ដែលឃើញច្បាស់រួមគ្នា ។*

ចប់អដ្ឋកថា បាណូបមសូត្រ ទី ១

# អដ្ឋកថា

## បឋមគិលានសុត្រទី ៤

[៤១៨] គប្បីជ្រាបវិនិច្ឆ័យក្នុង **បឋមគិលានសូត្រទី ៤** ។

[៤១៩] បទថា **និងអាពាធនោះ ដែលព្រះមហាកស្សបលះបង់បានហើយ (តថា បហីនោ ចាយស្មតោ មហាកស្សបស្ស សោ អាពាធោ អហោសិ)** សេចក្តីថា បានឮថា កាលព្រះមហាកស្សបត្ថេរ តាំងចិត្តស្តាប់ពោជ្ឈង្គភាវនានេះហើយ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលយើងចាក់ធ្លុះនូវសច្ចៈទាំងឡាយក្នុងថ្ងៃទី ៧ ចាប់ពីថ្ងៃដែលយើងបួសហើយ ពោជ្ឈង្គៈទាំងនេះក៏ប្រាកដ ។ ក៏កាលលោកគិតថា ឱហ្ន៎! ពាក្យទូន្មានរបស់ព្រះសាស្តានាំសត្វចេញអំពីទុក្ខ ដូច្នេះ លោហិតក៏ស្រស់ថ្លា ឧបាទាយរូប ក៏បរិសុទ្ធ ។ រោគក៏វិនាសបាត់ទៅអំពីកាយ ដូចដំណក់ទឹកធ្លាក់ក្នុងស្លឹកឈូក ដូច្នោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា **តថា បហីនោ ចាយ-ស្មតោ មហាកស្សបស្ស សោ អាពាធោ អហោសិ** ដូច្នេះ ។

សូម្បីក្នុងគិលានសូត្រទី ៤ ទីងទី ៥ ក៏មានន័យនេះដូចគ្នា ។

អាពាធដែលកើតពីភាពត្រជាក់តិចៗ ដែលកើតឡើងដោយការពាល់

ត្រូវជាមួយខ្យល់អំពីដើមឈើ មានផ្កាជាពិសដែលរីកហើយ ត្រង់ជើងភ្នំ គប្បីជ្រាបថា ជាអាពាធរបស់ជនសូម្បីទាំង ៣ នេះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយទាំងនោះឯង ។

ចប់អដ្ឋកថា បឋមគិលានសូត្រទី ៤

## ២.គិលានវគ្គោ (ដីកាចារ្យ)

### ១-៣.ចារណសុត្តាទិវណ្ណនា

យេសន្តិ យេសំ សត្តានំ។ ចត្តារោ ឥរិយាបថា អត្ថិ លព្ភន្តិ តទុបគសរីរាវយវលាភេន។ ឯតន្តិ "ចត្តារោ ឥរិយាបថេ កប្បេន្តី"តិ ឯតំ វចនំ។ "វិវេកនិស្សិត"ន្តិអាទិវចនតោ "សហវិបស្សនកេ មគ្គពោ-ជ្ឈង្គេ"ឥច្ចេវ វុត្តំ។ ទុតិយតតិយានិ ឧត្តានត្ថានេវ ហេដ្ឋា វុត្តនយត្តា។

### ៤-១០.បឋមគិលានសុត្តាទិវណ្ណនា

វិសុទ្ធំ អហោសិ វិសភាគធាតុក្ខោភំ វូបសមេន្តំ។ តេនាហ "បោក្ខរបត្តេ ...បេ... វិនិវត្តិត្វា គតោ"តិ។ ឯសេវ នយោ បាឡិតោ អត្ថតោ ច ចតុត្ថេន បញ្ចមឆដ្ឋានំ សមានត្តា។ វិសរុក្ខវាតសម្ផស្សេនាតិ វិសរុក្ខសន្និស្សិតវាតសម្ផស្សេន។ មន្ទសីតជរោតិ មុទុកោ សីតជរោ។ សេសន្តិ វុត្តាវសេសំ។

សព្ពត្ថាតិ សត្តមាទីសុ ចតូសុ។

គិលានវគ្គវណ្ណនា និដ្ឋិតា។

## គិលានវគ្គ (ដីកាចារ្យ)

### ការពណ៌នាអំពីចារណសូត្រជាដើម

បទថា យេសំ (ឯណា) មានសេចក្តីថា នៃសត្វទាំងឡាយឯណា ។ ឥរិយាបទ ៤ រមែងមានបានដោយការបានបំពោះចូលទៅគ្រប់គ្រងសរីរៈ និងអវៈយវៈនោះ ។ បទថា ឯតំ (នោះ) ពាក្យនោះ មានសេចក្តីថា រមែងគួរក្នុងឥរិយាបទ ៤ ។ បទថា វិវេកនិស្សិតំ (អាស្រ័យនៅក្នុងវិវេក) មានសេចក្តីថា អំពីពាក្យជាខាងដើម គឺលោកពោលថាដូច្នេះគឺ ក្នុងមគ្គនិងពោជ្ឈង្គ គឺអ្នកប្រកបព្រមដោយវិបស្សនា ។ ន័យទី ២ និងទី ៣ ព្រោះភាវៈនៃន័យគឺលោកពោលឲ្យរាក់ហើយ ។

### ការពណ៌នាគិលានសូត្រ ទី ១ ជាដើម

ការចូលទៅស្ងប់រម្ងាប់នោះ ជាការឃើញនូវធាតុផ្សេងគ្នា រមែងជាវិសុទ្ធិ ។ ព្រោះហេតុនោះទើបលោកពោលថា ក្នុងបាត្រស្លឹកពិណ ។ល។ ចូលទៅហើយត្រឡប់វិលវិញ ។ ក៏ព្រោះភាពស្មើគ្នានៃឋានៈទី ៥ និងទី ៦ ដោយអត្ថទី ៤ អំពីអត្ថព្រហបាលី ក៏ដូចជាន័យនោះឯង ។ បទថា វិសរុក្ខវាតសម្ផស្សេន (ដោយសម្ផស្សខ្យល់រុក្ខជាតិដូចពិសពស់) មានសេចក្តីថា ដោយការពាល់ត្រូវខ្យល់

ដែលអាស្រ័យនៅក្នុងរុក្ខជាតិដូចពិសពស់ ។ បទថា មន្ទសីតជរោ (ជរាព្រោះត្រជាក់ដ៏ទន់ខ្សោយ) មានសេចក្តីថា ជរាព្រោះត្រជាក់ដ៏ទន់ ។ ពាក្យថា សេសំ (ដ៏សេស) មានសេចក្តីថា ដូចលោកពោលហើយមិនមានសេស-សល់ ។ បទថា សព្វត្ថ (ក្នុងទីទាំងពួង) មានសេចក្តីថា ក្នុង ៤ មាន ៧ ដងជាដើម ។

(ការពណ៌នាអំពីគិលានវគ្គ ចប់)